# Tips

# កំពុងរង់ចាំលទ្ធផលតេស្តជំងឺកូវីដ-19?



**សូមអនុវត្តតាមដំណាក់កាលដ៏មានសារសំខាន់ទាំងនេះនៅពេលអ្នករង់ចាំលទ្ធផលតេស្តជំងឺកូវីដ-19 របស់អ្នកដើម្បីការពារការឆ្លងទៅអ្នកដទៃ។**

**ដំណាក់កាលទី 1៖** ត្រូវដាក់ខ្លួននៅដាច់ដោយឡែក (Self Isolate) នៅក្នុងផ្ទះ ក្នុង រយៈពេលដែលអ្នករង់ចាំលទ្ធផលតេស្តជំងឺកូវីដ-19។

**ដំណាក់កាលទី 2៖** ត្រូវប្រាប់សមាជិកគ្រួសារ ដៃគូររួមភេទ និងអ្នកថែទាំនៅក្នុងផ្ទះរបស់អ្នកថា អ្នកត្រូវនៅឆ្ងាយពីពួកគាត់ដើម្បីរក្សាសុវត្ថិភាពរបស់ពួកគាត់។ ប្រសិនបើមានពួកគាត់ណាម្នាក់បានប៉ះពាល់ផ្ទាល់ជាមួយអ្នក នោះពួកគាត់ត្រូវតែធ្វើចត្តាឡីស័ក (self quarantine)។

## របៀបដាក់ខ្លួននៅដាច់ដោយឡែក៖






- **ត្រូវនៅក្នុងផ្ទះ។**
- ត្រូវនៅក្នុងបន្ទប់ផ្ទាល់ខ្លួន និងឆ្ងាយពីអ្នកដទៃនៅក្នុងផ្ទះឱ្យបានច្រើនតាមដែលអាចធ្វើបាន។ **អ្នកត្រូវនៅឆ្ងាយពីមនុស្សដែលប្រឈមនឹងហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ** (higher risk of serious illness)។
- ត្រូវប្រើប្រាស់បន្ទប់ទឹកដាច់ដោយឡែក ប្រសិនបើអាច។
- អ្នកដែលចូលក្នុងបន្ទប់របស់អ្នក គួរពាក់ម៉ាស ប្រសិនបើអាច។ បន្ទាប់ពីចាកចេញពីបន្ទប់របស់អ្នក ពួកគាត់ត្រូវលាងដៃភ្លាមៗ បន្ទាប់មកត្រូវដោះម៉ាសនោះបោះចោលទៅក្នុងធុងសំរាមដែលមានគម្របបិទជិត ហើយត្រូវលាងដៃម្តងទៀត។
- មិនត្រូវរៀបចំអាហារសម្រាប់អ្នកដទៃ។
- មិនត្រូវមើលថែកុមារ ប្រសិនបើអាច។
- មិនត្រូវប៉ះពាល់សត្វចិញ្ចឹម ឬសត្វផ្សេងទៀត ប្រសិនបើអាច។
- មិនត្រូវអនុញ្ញាតឱ្យភ្ញៀវមកលេងផ្ទះរបស់អ្នក។
- មិនត្រូវប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ ជិះរថយន្តរួមគ្នា ឬជិះរថយន្តតាក់ស៊ីឡើយ។
- មិនត្រូវទៅធ្វើការ សាលារៀន ឬទីកន្លែងសាធារណៈឡើយ។

## ការពារការរីករាលដាលជំងឺកូវីដ-19

- **ត្រូវខ្ទប់មាត់នៅពេលក្អក និងកណ្តាស់។** នៅពេលក្អក ឬកណ្តាស់ ត្រូវខ្ទប់មាត់ និងច្រមុះរបស់អ្នកដោយប្រើក្រដាសជូតមាត់ ឬកណ្តាស់ដោយយកកែងដៃខ្ទប់មាត់។ មិនត្រូវក្អក ឬកណ្តាស់ដាក់បាតដៃរបស់អ្នកឡើយ។ បន្ទាប់ពីក្អក ឬកណ្តាស់ដាក់ក្រដាសជូតមាត់រួច ត្រូវបោះចោលវាទៅក្នុងធុងសំរាមដែលមានគម្របបិទជិត ហើយត្រូវលាងដៃរបស់អ្នកភ្លាមៗជាមួយសាប៊ូ និងទឹក ឱ្យបានយ៉ាងតិច 20 វិនាទី។
- ត្រូវលាងដៃឱ្យបានញឹកញាប់និងស្អាតល្អជាមួយសាប៊ូនិងទឹកឱ្យបានយ៉ាងតិច 20 វិនាទី។
- មិនត្រូវយកដៃកខ្វក់ប៉ះភ្នែក ច្រមុះ និងមាត់របស់អ្នកឡើយ។
- មិនត្រូវប្រើប្រាស់របស់ក្នុងផ្ទះរួមគ្នាជាមួយអ្នកដទៃឡើយ។
- ត្រូវលាងសម្អាត និងសម្លាប់មេរោគលើផ្ទៃ "ដែលមានការប៉ះពាល់ញឹកញាប់" ឱ្យបានរាល់ថ្ងៃ។
- ត្រូវអនុវត្តតាមការណែនាំស្តីពីការដាក់ខ្លួននៅដាច់ដោយឡែកនៅក្នុងផ្ទះរបស់មន្ទីរសុខភាពសាធារណៈខោនធី Alameda (Follow the Alameda County Public Health Department Home Isolation and Instructions)។





***អ្នកបានទទួលឯកសារនេះដោយសារអ្នកត្រូវបានធ្វើតេស្ត និងកំពុងរង់ចាំលទ្ធផល។***

Alameda County
Health Care Services Agency

Alameda County Public Health Department
Celebrating Healthy People in Healthy Communities

Colleen Chawla – Agency Director
Kimi Watkins-Tartt – Director
Nicholas Moss, MD – Interim Health Officer

**Contact**
Public Health Department:
(510) 267-8000 Main Line

COVID-19 Information:
(510) 268-2101

www.acphd.org